ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ....០០៧........អ.ស.ហ.គស

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារបច្ចេកទេសរៀបចំគោលការណ៍ណែនាំរួម សម្រាប់ការអនុវត្តការគ្រប់គ្រងលើប្រតិបត្តិការទ្រព្យឌីជីថល ឬទ្រព្យសកម្មគ្រីបតូ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង
## ជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ធ៧.០២៤.៧៣៥.ប្រ.ក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីប្រតិបត្តិការពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូ
- យោងតាមតម្រូវការចាំបាច់របស់និយ័តករមូលបត្រកម្ពុជា និងធនាគារជាតិនៃកម្ពុជា

## សម្រេច

**ប្រការ១** .-

ត្រូវបានបង្កើតក្រុមការងារបច្ចេកទេសរួមរវាងនិយ័តករមូលបត្រកម្ពុជា (ន.ម.ក.) និងធនាគារជាតិនៃកម្ពុជា ដើម្បីរៀបចំគោលការណ៍ណែនាំរួមសម្រាប់ការអនុវត្តការគ្រប់គ្រងលើប្រតិបត្តិការទ្រព្យឌីជីថល ឬទ្រព្យសកម្មគ្រីបតូ ដែលមានសមាសភាព ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្តមបណ្ឌិត **ទិន ភក្តី** | អគ្គនាយករង នៃ ន.ម.ក. | ប្រធាន |
| ២- | លោកស្រី **ម៉ក់ រស្មី** | អគ្គនាយករង នៃធនាគារជាតិនៃកម្ពុជា | អនុប្រធាន |
| ៣- | លោក **ឃុន គីមលៀង** | ប្រធាននាយកដ្ឋាន នៃ ន.ម.ក. | អនុប្រធាន |
| ៤- | លោក **ផាន់ ពិជ័យវិបុល** | ប្រធាននាយកដ្ឋាន នៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក.) | សមាជិក |
| ៥- | កញ្ញា **ទឹម ចាន់តារារ័ត្ន** | អនុប្រធាននាយកដ្ឋាន នៃ ន.ម.ក. | សមាជិកា |
| ៦- | លោក **ស៊ឹម ណារីកិត្យា** | អនុប្រធាននាយកដ្ឋាន នៃ ន.ម.ក. | សមាជិក |
| ៧- | លោក **គី សុខឡាយ** | អនុប្រធាននាយកដ្ឋាន នៃធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៨- | លោក **ហ៊ូ សិរី** | អនុប្រធាននាយកដ្ឋាន នៃធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៩- | លោកស្រី **ជា សុភ័ក្រ** | អនុប្រធាននាយកដ្ឋាន នៃធនាគារជាតិនៃកម្ពុជា | សមាជិកា |
| ១០- | កញ្ញា **ខ៊ូវ ចាន់ថុនា** | អនុប្រធាននាយកដ្ឋាន នៃធនាគារជាតិនៃកម្ពុជា | សមាជិកា |
| ១១- | លោក **ពេជ្រ រិទ្ធី** | ប្រធានការិយាល័យ នៃ ន.ម.ក. | សមាជិក និង ជាលេខាធិការ |
| ១២- | លោក **លឹម ហៀង** | ប្រធានការិយាល័យ នៃ ន.ម.ក. | សមាជិក |
| ១៣- | លោក **ផាត់ សុជាតិ** | ប្រធានការិយាល័យ នៃ ន.ម.ក. | សមាជិក |
| ១៤- | លោក **ហ៊ិន ផានិត** | ប្រធានការិយាល័យ នៃ ន.ម.ក. | សមាជិក |
| ១៥- | កញ្ញា **អៀម អេរីយ៉ែល** | ប្រធានការិយាល័យ នៃធនាគារជាតិនៃកម្ពុជា | សមាជិកា |
| ១៦- | លោក **រិន ចំរ៉ុង** | អនុប្រធានការិយាល័យ នៃ ន.ម.ក. | សមាជិក |

| | | |
|---|---|---|
| ១៧- លោក **ចំរើន សិរីបុត្រ** | អនុប្រធានការិយាល័យ នៃ ន.ម.ក. | សមាជិក |
| ១៨- លោក **រស់ សុរៈវឌ្ឍនៈ** | អនុប្រធានការិយាល័យ នៃ ន.ម.ក. | សមាជិក |
| ១៩- កញ្ញា **រឿង សុវណ្ណារ៉ា** | អនុប្រធានការិយាល័យ នៃធនាគារជាតិនៃកម្ពុជា | សមាជិកា |
| ២០- លោក **ប៉ុន ឆ្វារ៉ាមី** | អនុប្រធានការិយាល័យ នៃធនាគារជាតិនៃកម្ពុជា | សមាជិក |
| ២១- លោក **សាន់ ពៅច័ន្ទ** | អនុប្រធានការិយាល័យ នៃ ស.ហ.ក. | សមាជិក |
| ២២- កញ្ញា **ឈឹម សុទ្ធាណា** | ប្រធានផ្នែក នៃធនាគារជាតិនៃកម្ពុជា | សមាជិកា |
| ២៣- លោក **សំបាន់ វិបុល** | ប្រធានផ្នែក នៃធនាគារជាតិនៃកម្ពុជា | សមាជិក |
| ២៤- លោក **អ៊ុំ សិរីរតនៈ** | ប្រធានផ្នែក នៃធនាគារជាតិនៃកម្ពុជា | សមាជិក |
| ២៥- កញ្ញា **សុខ ដួរ** | អនុប្រធានផ្នែក នៃធនាគារជាតិនៃកម្ពុជា | សមាជិកា |
| ២៦- កញ្ញា **ហេង សុជាតិតា** | មន្ត្រីនៃ ន.ម.ក. | សមាជិកា |
| ២៧- លោក **រត្ន វីរៈវឌ្ឍ** | មន្ត្រីនៃ ន.ម.ក. | សមាជិក |
| ២៨- កញ្ញា **ហួត វិច្ឆិកា** | មន្ត្រីនៃ ន.ម.ក. | សមាជិកា |
| ២៩- កញ្ញា **អូន សុខណៃ** | មន្ត្រីនៃ ន.ម.ក. | សមាជិកា |
| ៣០- លោក **ឌួខ វិរៈ** | បុគ្គលិកនៃ ស.ហ.ក. | សមាជិក។ |

**ប្រការ២ .-**

ក្រុមការងារបច្ចេកទេសរៀបចំគោលការណ៍ណែនាំរួមសម្រាប់ការអនុវត្តការគ្រប់គ្រងលើប្រតិបត្តិការទ្រព្យឌីជីថល ឬទ្រព្យសកម្មគ្រីបតូ មានមុខងារ និងភារកិច្ច ដូចខាងក្រោម៖

- សិក្សា ស្រាវជ្រាវ ប្រមូល និងវិភាគអំពីទិដ្ឋភាពនិងការវិវត្តនៃបទប្បញ្ញត្តិ ក្របខ័ណ្ឌគោលនយោបាយ អនុសាសន៍របស់អង្គការកំណត់ស្តង់ដាអន្តរជាតិក្នុងវិស័យហិរញ្ញវត្ថុ ឧត្តមានុវត្តន៍អន្តរជាតិ និងសេចក្តីណែនាំផ្សេងៗ ពាក់ព័ន្ធនឹងការគ្រប់គ្រងលើប្រតិបត្តិការទ្រព្យឌីជីថល ឬទ្រព្យសកម្មគ្រីបតូក្នុងប្រទេសកម្ពុជា និងបណ្តាប្រទេសផ្សេងៗ
- សម្របសម្រួល និងរៀបចំគោលការណ៍ណែនាំរួមសម្រាប់កំណត់វិសាលភាពនិងដែនសមត្ថកិច្ចក្នុងការអនុវត្តការគ្រប់គ្រងប្រទាក់ក្រឡាគ្នារវាង ន.ម.ក. និងធនាគារជាតិនៃកម្ពុជា និងការទទួលខុសត្រូវលើការរៀបចំបទប្បញ្ញត្តិពាក់ព័ន្ធនឹងប្រតិបត្តិការទ្រព្យឌីជីថល ឬទ្រព្យសកម្មគ្រីបតូ
- ពិនិត្យ ពិភាក្សា និងផ្តល់យោបល់លើសេចក្តីព្រាងបទប្បញ្ញត្តិពាក់ព័ន្ធនឹងទ្រព្យឌីជីថល ឬទ្រព្យសកម្មគ្រីបតូ ដែលរៀបចំដោយ ន.ម.ក. ឬធនាគារជាតិនៃកម្ពុជា
- បំពេញភារកិច្ចពាក់ព័ន្ធផ្សេងទៀត តាមការណែនាំរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និង/ឬធនាគារជាតិនៃកម្ពុជា។

**ប្រការ៣ .-**

ការរៀបចំ និងការអនុវត្តការងារទាំងឡាយស្របតាមសេចក្តីសម្រេចនេះ គឺត្រូវធ្វើឡើងដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន ព្រមទាំងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និងគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨ របស់រាជរដ្ឋាភិបាលកម្ពុជា។

**ប្រការ៤ .-**

អនុប្រធាន និងសមាជិក-សមាជិកា នៃក្រុមការងារបច្ចេកទេសរៀបចំគោលការណ៍ណែនាំរួមសម្រាប់ការអនុវត្តការគ្រប់គ្រងលើប្រតិបត្តិការទ្រព្យឌីជីថល ឬទ្រព្យសកម្មគ្រីបតូ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ។

**ប្រការ៥ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

ទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃ ន.ម.ក. ប្រធាននាយកដ្ឋាន-អង្គភាពចំណុះឱ្យ ន.ម.ក. និងធនាគារជាតិនៃកម្ពុជា ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តខ្លឹមសារនៃសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៧កើត ខែ អាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែ កក្កដា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពនិងសមាសភាពក្រុមប្រឹក្សានៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៦
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ